# មជ្ឈមណ្ឌលខេមរសិក្សា

ដោយបណ្ឌិត ហ៊្វីលីព្ភ ប៊ីុកាំ នាយកស្ដីទី

នៅពេលដែលមជ្ឈមណ្ឌលខេមរសិក្សាចាប់មានរូបរាងឡើង នាយកស្ដីទីរបស់មជ្ឈមណ្ឌលសូមជូនសេចក្ដីរៀបរាប់អំពីគម្រោងការនេះ ហើយសូមអញ្ជើញប្រិយមិត្តអ្នកអានព្រឹត្តិបត្រនេះ មេត្តាចូលរួមនិងជួយគាំទ្រគម្រោងការថ្មីនេះ ។

## ដើមកំណើតនៃមជ្ឈមណ្ឌលខេមរសិក្សា (ម.ខ.ស.)

នៅខែមករា ឆ្នាំ ១៩៩៩ មនុស្សដែលមានបទពិសោធន៍និងការអប់រំប្លែក ៗ ពីគ្នានៅក្នុងផ្នែកការរក្សាស្រាវជ្រាវ និងប្រវត្តិសាស្ត្រ ហើយដែលអញ្ជើញមកពីប្រទេសកម្ពុជានិងបរទេស បានមកជួបជុំគ្នាក្នុងសន្និសីទ ដែលមូលនិធិប្រាសាទបុរាណពិភពលោកបាន រៀបចំនៅរាជធានីភ្នំពេញនិងនៅទីរួមខេត្តសៀមរាប ។ អ្នកចូលរួមបានពិភាក្សារិះរកមធ្យោបាយលើកកម្រិតឧត្តមសិក្សា និងការស្រាវជ្រាវជាន់ខ្ពស់នៅប្រទេសកម្ពុជា ដោយបើកមជ្ឈមណ្ឌល ១ ដែលជម្រុញឲ្យមានការប្តូរផ្តោះជាមួយអន្តរជាតិក្នុងមុខវិជ្ជាផ្សេង ៗ ខាងវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ ដែលទាក់ទងទៅនឹងបេតិកភ័ណ្ឌវប្បធម៌ខ្មែរ ។

សន្និសីទនេះ ពិតជាមានពហុភាព បើគិតដល់ស្ថាប័នដែលអញ្ជើញមក ហើយមានការពិភាក្សាគ្រប់យ៉ាង អំពីអនុស្ថាប័ន ដែលមជ្ឈមណ្ឌលត្រូវមាន ។ គួរថ្លែងអំណរគុណចំពោះអ្នកផ្តើមគំនិតគម្រោងការនៅដំណាក់កាលដំបូង ហើយជាពិសេសចំពោះអ្នករៀបចំសន្និសីទខែមករា អំពីការណ៍ ដែលលោកទាំងអស់នេះ ហ៊ានមើលហួសពីក្របខ័ណ្ឌឯកទេសភាពដែលមានកំណត់របស់ខ្លួន ដើម្បីរាប់បញ្ចូលក្រសោបរឿង “សិក្សាខ្មែរ” យ៉ាងទូលំទូលាយ ។

នៅក្នុងចំណោមភាគីកម្ពុជាដែលវត្តមាន មាន ៖ អាជ្ញាធរអប្សរា (អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ), ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ហើយនិងអ្នកតំណាងសាកលវិទ្យាល័យទាំងពីរដែលមានចំណាប់អារម្មណ៍ពិសេស ពោលគឺ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលមានការចាប់អារម្មណ៍យ៉ាងពិសេសទៅលើវិស័យដែលមជ្ឈមណ្ឌលយកចិត្តទុកដាក់ គឺ វិទ្យា-សាស្ត្រសង្គមនិងមនុស្សសាស្ត្រ ។

នៅក្នុងចំណោមស្ថាប័នបរទេសដែលវត្តមាន មាន ៖ មូលនិធិប្រាសាទបុរាណពិភពលោក, សាកលវិទ្យាល័យយ៉េលនៃល្វ (សហរដ្ឋ), សាកល-វិទ្យាល័យហាវ៉ៃ (សហរដ្ឋ), សាកលវិទ្យាល័យជាតិសិង្ហបុរី (សាំងហ្គាពួរ), សាកលវិទ្យាល័យខែនប៊ឺរ៉ា (អូស្ត្រាលី), សាលាសិក្សាបូព៌ាប្រទេសនិងអាហ្វ្រិក (ក្រុងឡុងដ៍ ប្រទេសអង់គ្លេស), សាកលវិទ្យាល័យប៉ិន្ទ (អាឡឺម៉ង់), សាកលវិទ្យាល័យវ៉ាស៊ីនតោន (ក្រុងសីអាតឹល សហរដ្ឋ), សាលាប្រតិបត្តិសិក្សាជាន់ខ្ពស់ (École Pratique des Hautes Études) (ក្រុងប៉ារីស ប្រទេសបារាំង), វិទ្យាស្ថានបារាំងសែសនៃចុងបូព៌ា, សាកលវិទ្យាល័យផ្ទរីដ ជាដើម ដែរ ។ អ្នកតំណាងអង្គការយូណេស្កូនិងក្រុមប្រឹក្សាបណ្ដាមជ្ឈមណ្ឌល ស្រាវជ្រាវអាមេរិកាំងឯនាយសមុទ្រ (ប្រ.ម.ស្រ.អា.ឯ.) ព្រមទាំងនាយកសេវាកម្មផ្តល់ពត៌មានអាមេរិកាំងរបស់ស្ថានអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ក៏បានអញ្ជើញមកប្រជុំផងដែរ ។

អង្គសន្និសីទបានយល់ព្រមឲ្យក្រុម ១ ដែលសមាជិកជាស្ថាប័ន ១ ចំនួន ដែលបានមករួមក្នុងសន្និសីទ និង ១ ចំនួនទៀតជាស្ថាប័នដទៃទៀត បង្កើតមជ្ឈមណ្ឌល ១ ។

## បេសកកម្មរបស់មជ្ឈមណ្ឌលខេមរសិក្សា

យើងអាចពណ៌នាអំពី ម.ខ.ស. បានយ៉ាងល្អបំផុត តាមរយៈគោលបំណងទាំងបី ដែលទាក់ទងគ្នាទៅវិញទៅមក ៖ ការស្រាវជ្រាវ ការបង្រៀន និងសេវាសាធារណៈ ។

បណ្ដាកម្មវិធីពហុមុខវិជ្ជាត្រូវបានបង្កើត ដើម្បីសម្រួលការស្រាវជ្រាវក្នុងវិស័យសិក្សា, ការបង្រៀន ហើយនិងសកម្មភាពសេវាសាធារណៈ ដែលនាំមក នូវការយល់ដឹងយ៉ាងទូលំទូលាយនូវអារ្យធម៌ខ្មែរតាមរយៈការចាប់ផ្តើមទាក់ទងនឹងភូមិភាគអាស៊ីអាគ្នេយ៍ ។ មជ្ឈមណ្ឌលឧទ្ទិសទៅលើការរិះរកផ្នែកសិក្សា និងទៅលើការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ ។ ដោយអភិវឌ្ឍ និង ធានាកម្មវិធីទាំងនេះ មជ្ឈមណ្ឌលមានបំណងនឹងជម្រុញឲ្យកើនឡើង នូវទំនាក់ទំនងរវាងស្ថាប័នឧត្តមសិក្សានៅប្រទេសកម្ពុជា សាកលវិទ្យាល័យបរទេស អង្គការក្រៅរដ្ឋាភិបាលផ្នែកមនុស្ស-សាស្ត្រ ហើយនិងរាជរដ្ឋាភិបាលកម្ពុជា ។

- **ការស្រាវជ្រាវ**

អនាគតរបស់សិក្សាខ្មែរពឹងផ្អែកទៅលើការស្រាវជ្រាវ ។ គោលដៅសំខាន់មួយរបស់មជ្ឈមណ្ឌល គឺ ផ្សព្វផ្សាយសកម្មភាពស្រាវជ្រាវនៅប្រទេសខ្មែរ ដោយមានទំនាក់ទំនងយ៉ាងសកម្ម ដោយមានការពិភាក្សាតទល់ និងមានសហការរវាងអ្នកស្រាវជ្រាវខ្មែរនិងបរទេស ។

សមាជិករបស់មជ្ឈមណ្ឌល និងអ្នកស្រាវជ្រាវដែលជាភ្ញៀវ នឹងដឹកនាំការស្រាវជ្រាវ ។ មជ្ឈមណ្ឌលនឹងអញ្ជើញអ្នកប្រាជ្ញខ្មែរនិងអន្តរជាតិឲ្យមកទំនុកបម្រុងការស្រាវជ្រាវគ្រប់ថ្នាក់សិក្សា រហូតដល់ថ្នាក់ជាន់ខ្ពស់នៅ

សាកលវិទ្យាល័យនិងថ្នាក់ស្រាវជ្រាវក្រោយពីថ្នាក់បណ្ឌិត ។ ការស្រាវជ្រាវត្រូវមានការពាក់ព័ន្ធនឹងអារ្យធម៌ខ្មែរ និងភាគច្រើនត្រូវធ្វើនៅប្រទេសខ្មែរ ឬ នឹងបញ្ជូននិស្សិតទៅស្ថាប័នឯបរទេសដែលមានសារប័ណ្ណដ្ឋាន និងសមត្ថភាពជួយណែនាំនិស្សិត ។

ក្នុងការជ្រើសរើសសមាជិក មជ្ឈមណ្ឌលនឹងឲ្យអាទិភាពទៅលើវិស័យស្រាវជ្រាវណា ដែលពុំសូវមានមនុស្ស ។ ម្យ៉ាងទៀត គេនឹងជម្រុញទឹកចិត្តស្ថាប័នបរទេសដែលជាដៃគូ ដើម្បីឲ្យធានាអាហារូបករណ៍ស្រាវជ្រាវ មុខវិជ្ជាបង្រៀន និង អាសនៈ ជារយៈពេលខ្លីឬយូរ ដើម្បីទំនុកបម្រុងកម្មវិធីស្រាវជ្រាវ ដែលមានប្រយោជន៍ពិសេស ។ ការអភិវឌ្ឍបណ្ណាល័យ ១ នៅមជ្ឈមណ្ឌល នឹងធ្វើឲ្យមានការផ្ញើទៅផ្ញើមកនូវឯកសារពិគ្រោះនិងអត្ថបទតាមរយៈប្រព័ន្ធអ៊ិនធឺណេត ដោយឥតគិតថ្លៃ ។ នៅខេត្តសៀមរាប បណ្ណាល័យជាទីកន្លែងសម្រាប់អានសៀវភៅ ប្រមូលពត៌មាន ស្ដាប់សិក្ខាសាលា និងពិគ្រោះគម្រោងការដែលកំពុងប្រតិបត្តិ ។

### • ការបង្រៀន

ការបង្រៀនជាសកម្មភាពសំខាន់បំផុត ដោយមានវត្តមាន សមាជិក, អ្នកស្រាវជ្រាវដែលជាភ្ញៀវ និង និស្សិតសាកលវិទ្យាល័យ ។ មជ្ឈមណ្ឌលមានបំណងសម្រាប់ធ្វើជាកន្លែងបង្រៀនមុខវិជ្ជាផ្សេង ៗ ក្នុងវិស័យ ១ ចំនួនធំដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រ និងអារ្យធម៌ខ្មែរ ។

មជ្ឈមណ្ឌលខេមរសិក្សាមានគោលបំណងជួយក្នុងការពង្រឹងការស្រាវជ្រាវនិងការបង្រៀន នៅប្រទេសកម្ពុជា ហើយមជ្ឈមណ្ឌលនឹងប្រតិបត្តិ ដោយមានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយនឹងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ហើយនិងស្ថាប័នកម្ពុជាដទៃទៀត ។

គេនឹងបង្កើតកម្មវិធីសិក្សាយ៉ាងហ្មត់ចត់ ដើម្បីបង្គ្រប់កម្មវិធីដែលមានស្រាប់នៅស្ថាប័នឧត្តមសិក្សាកម្ពុជា ហើយដើម្បីគិតគូរដល់សេចក្ដីត្រូវការរបស់ស្ថាប័នដែលជាសមាជិកក្នុងក្រុមស្ថាប័ន ។ នៅក្នុងដំណាក់កាលដំបូងនេះ យើងខ្ញុំប៉ុនប៉ងនឹងធ្វើឲ្យកម្មវិធីសិក្សាអាចប្រែប្រួលទៅតាមទេសកាល និង ឲ្យមុខវិជ្ជានឹងអាចរៀនបានក្នុងក្របខ័ណ្ឌរោងជាង រយៈពេលពី ៣ ថ្ងៃ រហូតដល់សិក្ខាសាលាឧត្តមសិក្សា ១ ឆមាស ។

មជ្ឈមណ្ឌលប៉ុនប៉ងបញ្ចេញវិញ្ញាបនប័ត្រនៅក្នុងពេលអនាគត ។ ក្របខ័ណ្ឌសម្រាប់បានទីតិសម្បទា នឹងត្រូវគិតគូរតែក្រោយពីពេលសមាជិកនៃក្រុមស្ថាប័ន បានឯកភាពគ្នាយ៉ាងសម្រេច និងមានការពិគ្រោះយ៉ាងពេញលេញជាមួយនឹងក្រសួងដែលពាក់ព័ន្ធ ។

### • សេវាសាធារណៈ

សេវាសាធារណៈ គឺជាបេសកកម្មដ៏សំខាន់ ១ របស់មជ្ឈមណ្ឌល ដោយយល់ដល់តម្រូវការ ដែលពឹងផ្អែកលើការអប់រំ និងការស្រាវជ្រាវ នៅប្រទេសខ្មែរ តែស្ថិតនៅក្រៅសាកលវិទ្យាល័យ ។ សេវាបម្រើសាធារណៈនឹងធ្វើជាមធ្យោបាយ ១ ដើម្បីជម្រាបអ្នកស្រាវជ្រាវ អ្នកវិជ្ជាជីវៈ ហើយនិងមហាជនទូទៅ នៅប្រទេសកម្ពុជានិងនៅបរទេស ឲ្យជ្រាបអំពីការស្រាវជ្រាវនិងមុខវិជ្ជាសិក្សានៅមជ្ឈមណ្ឌល ។

ជាទូទៅ មានការគ្រោងទុកថា មជ្ឈមណ្ឌលជាស្ពានដើម្បីភ្ជាប់បណ្ដើមគំនិត ដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា ជាមួយនឹងបណ្ដើមគំនិត ដែលមានមូលដ្ឋាននៅបរទេស ហើយដែលទាក់ទងទៅនឹងបេតិកភ័ណ្ឌវប្បធម៌ខ្មែរ ។ ម្ល៉ោះហើយ មជ្ឈមណ្ឌលនឹងទទួលធ្វើឃោសនា និងផ្សព្វផ្សាយសកម្មភាពទាំងនោះនៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសកម្ពុជា ។ ពត៌មាននឹងផ្សព្វផ្សាយតាមរយៈមធ្យោបាយផ្សេង ៗ ដូចជា ព្រឹត្តិប័ត្រក្រដាសនេះ ប្រព័ន្ធអ៊ិនធឺណេត (វ៉ិបសាយថ៍) ការបោះពុម្ពផ្សាយ ហើយនិងសន្និសីទ ជាដើម ។ លើសពីនេះទៀត មជ្ឈមណ្ឌលនឹងរក្សាទុកឯកសារ, សម្ភារៈយោង និងបរិក្ខារមូលដ្ឋាន ដើម្បីផ្គត់ផ្គង់កម្មវិធីសិក្សាផ្នែកប្រវត្តិសាស្ត្រ ភាសា និងវប្បធម៌ សម្រាប់អ្នកសៀមរាបតែម្ដង ដែលអាចធ្វើការជាមួយសាលារៀនក្នុងតំបន់ តាមរយៈកម្មវិធីដែលឧទ្ទិសចំពោះប្រជាជនក្នុងតំបន់ ហើយដែលមានគោលបំណងនឹងធ្វើឲ្យការប៉ិនប្រសប់ខាងការបង្រៀនក្នុងសាលារៀន កាន់តែល្អឡើង ។

## ការរៀបចំផ្នែកស្ថាប័ន និង ការចាត់ការរបស់មជ្ឈ-មណ្ឌលខេមរសិក្សា

### • ក្របខ័ណ្ឌនីត្យានុកូលនិងស្ថាប័ន

មជ្ឈមណ្ឌលខេមរសិក្សាបានចុះបញ្ជី នៅប្រទេសកម្ពុជា និងនៅសហរដ្ឋ ជាអង្គការអន្តរជាតិ ក្រៅរដ្ឋាភិបាល ខាងសិក្សាធិការ និងដែលគ្មានបំណងរកផលកម្រៃ ។ រាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងអប់រំ យុវជន និងកីឡា ហើយនិងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានចុះហត្ថលេខាលើពិធីសារនៃកិច្ចព្រមព្រៀង ១ ជាមួយនឹងមជ្ឈមណ្ឌលខេមរសិក្សា ។

មជ្ឈមណ្ឌលខេមរសិក្សាចូលក្នុងក្រុម ១ (សហាគម) ដែលនៅក្នុងនេះ មានស្ថាប័នកម្ពុជានិងបរទេស ដែលជាដៃគូនិងជាស្ថាប័នដ៏សំខាន់ក្នុងវិស័យអប់រំ ឬ ស្រាវជ្រាវ ។

នៅក្នុងចំណោមដៃគូកម្ពុជារបស់មជ្ឈមណ្ឌល មានសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (ស.ភ.វ.ស.) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.) ហើយនិងអាជ្ញាធរអប្សរា (អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ) ។

នៅក្នុងចំណោមសមាជិកបរទេសនៃក្រុមស្ថាប័ន មានមូលនិធិប្រាសាទបុរាណពិភពលោក សមាគមទ្វីបអាស៊ី សាកលវិទ្យាល័យយ៉េនែល (សហរដ្ឋ) សាកលវិទ្យាល័យហាវៃនៅម៉ាណូអា (សហរដ្ឋ) សាកលវិទ្យាល័យជាតិសិង្ហបុរី (សាំងហ្គាពួរ) ហើយនិងសាកលវិទ្យាល័យរដ្ឋវ៉ាស៊ីនតោន (សហរដ្ឋ) ។ ស្ថាប័នឯទៀតដែលមានការចាប់អារម្មណ៍មាន ៖ សាលាសិក្សាបូព៌ាប្រទេសនិងអាហ្វ្រិក ដែលចូលក្នុងចំណោមវិទ្យាស្ថានរបស់សាកវិទ្យាល័យឡុងដ៍ (ប្រទេសអង់គ្លេស), សាកលវិទ្យាល័យប៉ារីសទី ៧ ដឺនីស៍-ឌីដ្រូត៍ (ប្រទេសបារាំង), សាកលវិទ្យាល័យប៊ិន្ទ (ប្រទេសអាឡឺម៉ង់), សាកលវិទ្យាល័យខែនប៊ឺរ៉ា (អូស្ត្រាលី) ហើយនិងសាកលវិទ្យាល័យផ្លូរីដ (សហរដ្ឋ) ។

ដែគូក្នុងវិស័យសិក្សានិងវិជ្ជាជីវៈទាំងនោះ នឹងផ្តល់សេចក្តីណែនាំខាងយុទ្ធសាស្ត្រ ជានាសមាជិករបស់មជ្ឈមណ្ឌល ហើយនិងជួយឧបត្ថម្ភការបង្កើតកម្មវិធីសិក្សាឲ្យទាន់សម័យ ។

ក្រុមប្រឹក្សាភិបាល នឹងកាន់កាប់ផ្នែកហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌល ។ នាយកនិងបុគ្គលិករបស់មជ្ឈមណ្ឌល នឹងមើលខុសត្រូវលើការចាត់ការកម្មវិធីទាំងឡាយជារៀងរាល់ថ្ងៃ ។ គណៈកម្មាធិការចាត់ការ នឹងធ្វើការជាមួយនឹងនាយកនិងបុគ្គលិក ដើម្បីទាញយកផលប្រយោជន៍ខ្ពស់បំផុតពីសមាជិកនៃសហាគម (ក្រុមស្ថាប័ន), ត្រួតពិនិត្យលទ្ធផល ហើយនិងជ្រើសរើសអ្នកចូលរួមក្នុងកម្មវិធីសិក្សារបស់មជ្ឈមណ្ឌល ។ សមាជិកស្រាវជ្រាវ អ្នកស្រាវជ្រាវនៅទីកន្លែង និងនៅក្នុងអន្តេវាសិក ហើយនិងនិស្សិតសាកលវិទ្យាល័យដែលនៅទីកន្លែង នឹងគ្រប់គ្រងមុខវិជ្ជាសិក្សារបស់មជ្ឈមណ្ឌល ។

## • ដំណាក់កាលដំបូងនៃវឌ្ឍនភាព (កញ្ញា ១៩៩៩–ចុងឆ្នាំ ២000)

ទន្ទឹមគ្នានឹងការស្ថាបនាផ្នែកស្ថាប័ននៃ ម.ខ.ស. សមាជិក ១ ក្រុមនៅប្រទេសកម្ពុជា បានធ្វើការដើម្បីសម្រេចគោលដៅខ្លះដែលគេបានកំណត់ សម្រាប់ឆ្នាំ ១៩៩៩-២000 ។

នៅក្នុងចំណោមកិច្ចការដែលបានបំពេញរួចហើយ មាន ៖

_ ការរកឃើញទីស្នាក់ការបណ្តោះអាសន្ន
_ ការប្រមូលផ្តុំគន្ថនិទ្ទេសស្តីពីធនធានឯកសារ
_ ការរៀបចំព្រឹត្តិប័ត្រជា ៣ ភាសា និងរៀបចំវិបសាយថ៍
_ ការរៀបចំបញ្ជីមូលដ្ឋានទិន្នន័យ ដែលរាយឈ្មោះមនុស្សនិងស្ថាប័នទាំងឡាយ ដែលមានចំណាប់អារម្មណ៍ទៅលើសិក្សាខ្មែរ នៅប្រទេសកម្ពុជានិងនៅទូទាំងពិភពលោក ។

## _ ការរកឃើញទីស្នាក់ការបណ្តោះអាសន្ន

យើងខ្ញុំបានយកចិត្តទុកដាក់ជាខ្លាំងចំពោះអគារ ២ ខ្នង នៅក្នុងវត្តដំណាក់ ដែលស្ថិតនៅកណ្តាលក្រុងសៀមរាប ។ អគារនេះ ធ្លាប់ប្រើជាសាលាពុទ្ធិកបឋមសិក្សា រហូតដល់ពេលវាត្រូវខូចខាតនៅជំនាន់ខ្មែរក្រហម ។ យើងខ្ញុំបានទទួលសេចក្តីអនុញ្ញាតពីគណៈកម្មាធិការអាចារ្យនិងចៅអធិការវត្តដំណាក់, ក្រសួងធម្មការនិងសាសនា ហើយនិងអាជ្ញាធរតំបន់ទាំងឡាយ ។ ការជួសជុលអគារ ចាប់ផ្តើមហើយ ។ យើងខ្ញុំបានចាប់ផ្តើមជួសជុលអគារទី ១ ដែលនឹងយកធ្វើជាបណ្ណាល័យ ។

ការជួសជុលស្តារគ្រោងអគារត្រូវតែបញ្ចប់នៅខែកក្កដា ឆ្នាំ ២000 តាមការប្រមាណ ។ ការជួសជុលស្តារអគារទី ២ ដែលនឹងយកធ្វើជារោងសន្និសីទនិងពិព័រណ៍ ត្រូវបង្ហើយប្រហែលនៅខែវិច្ឆិកា ឆ្នាំ ២000 តាមការប្រមាណ តែអាចមានការយឺតយ៉ាវនៅរដូវវស្សា ។ យើងខ្ញុំក៏គិតសង់អគារ ១ ទៀតឡើងវិញ នៅលើគ្រឹះចាស់របស់ផ្ទះឈើ ១ ខ្នង ដែលភ្លើងឆេះអស់នៅក្នុងសង្គ្រាម ។ អគារទី ៣ នេះ សម្រាប់ដាក់ថ្នាក់រៀន និងការិយាល័យទាំងឡាយ ។

ដោយសារតែមានសប្បុរសជន ១ នាក់ ជាអ្នកឧបត្ថម្ភ យើងខ្ញុំនឹងចាប់សង់ផ្នែកបន្ថែម ឲ្យសាលារៀនបឋមសិក្សា ដែលនៅជិតអគាររបស់មជ្ឈមណ្ឌល ។

## _ ការប្រមូលផ្តុំគន្ថនិទ្ទេស (សរុបសៀវភៅ) អំពីធនធានឯកសារ

សមាជិក បណ្ឌិត វិល្លៀម សោធវើរ៍ធ កំពុងព្យាយាមប្រមូលផ្តុំបញ្ជីចំណងជើងសៀវភៅ ដែលចាំបាច់ក្នុងវិស័យវិទ្យាសាស្ត្រសង្គមអំពីប្រទេសកម្ពុជានិងអាស៊ីអាគ្នេយ៍ ។ មកដល់ពេលនេះ គាត់បានខិតខំស្វែងរកខាងប្រវត្តិសាស្ត្របុរាណ ប្រវត្តិសិល្បៈ (សម័យមុនអង្គរនិងសម័យអង្គរ) និងបុរាណវិទ្យា ហើយគាត់បានបញ្ជី ១ ចំនួនធំហើយ ។ យើងខ្ញុំមានបំណងស្វែងរកខាងវិស័យឯទៀតនៃវិទ្យាសង្គម ដូចជា នរវិទ្យា ជាតិពន្ធុវិទ្យា សង្គមវិជ្ជា ហើយនិងភាសាសាស្ត្រ និងប្រវត្តិសាស្ត្រសម័យទំនើប ថែមទៀតផង ។ គោលបំណង គឺធ្វើបញ្ជីសៀវភៅឲ្យគ្រប់ក្នុងវិស័យនីមួយ ៗ ដែលមជ្ឈមណ្ឌលត្រូវទិញជាអាទិភាព ។ យើងខ្ញុំកំពុងចុះបញ្ជីសៀវភៅដែលយើងបាន ១ ចំនួនហើយ ។ ការងារត្រូវតែធ្វើតទៅទៀត ជាពិសេសចំណែកវិធីធ្វើ និងចំណែកឯកសារ ។ ក្នុងគោលដៅនេះ យើងខ្ញុំមានបំណងស្វែងរកការជួយឧបត្ថម្ភ ពីអ្នកស្រាវជ្រាវឯទៀត នៅប្រទេសកម្ពុជានិងនៅបរទេស ។ យើងខ្ញុំសង្ឃឹមថានឹងអាចទិញសៀវភៅ ដោយសារការជួយផ្នែកថវិកា ពីឯកជន ឬស្ថាប័ននានា ។

ក្នុងចំណោមគំនិតទាំងឡាយដើម្បីឲ្យបណ្ណាល័យមានសៀវភៅបរិបូណ៌ យើងខ្ញុំគិតធ្វើកម្មវិធី ១ ដើម្បីរកទិញ និងចុះបញ្ជីសៀវភៅនិងទស្សនាវដ្តីដែលបោះពុម្ពផ្សាយនៅប្រទេសកម្ពុជា ។ គំនិត ១ ទៀត គឺប្រមូលសារណានិងនិក្ខេបបទស្តីអំពីប្រទេសកម្ពុជានិងសិក្សាខ្មែរ ដែលគេបានធ្វើក្នុងកំឡុងពេល ១០ ទៅ ២០ ឆ្នាំកន្លងមកនេះ នៅប្រទេស កម្ពុជានិងនៅបរទេស ។

## _ ការរៀបចំព្រឹត្តិប័ត្រជា ៣ ភាសា និងការរៀបចំវិបសាយថ៍

គឺលោក មីស្ហែល ឫទ្ធី អង់តែល្ម ដែលបានធ្វើការរៀបចំព្រឹត្តិប័ត្រសិក្សាចក្រនេះ ដែលមានប្រើ ៣ ភាសា ពោលគឺ ភាសាខ្មែរ អង់គ្លេស និងបារាំង សម្រាប់មហាជនដែលជានិស្សិតនិងសាស្ត្រាចារ្យ និងមហាជនទូទៅ ។ គំនិតទូទៅក្នុងគម្រោងការព្រឹត្តិប័ត្រនេះ គឺជម្រាបជនកម្ពុជា ជាពិសេសនិស្សិតកម្ពុជា ឲ្យដឹងអំពីអ្វីដែលគេបានសម្រេចនិងបំពេញក្រៅប្រទេសកម្ពុជាក្នុងវិស័យ “សិក្សាខ្មែរ” ហើយនៅក្នុងពេលជាមួយគ្នា ក៏សូមជម្រាបនិស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ អំពីបណ្តើមគំនិតដែលកំពុងតែមាននៅប្រទេសកម្ពុជា ។ ចំពោះកម្មវិធីនេះ យើងខ្ញុំក៏រីករាយ បើសិនបានទទួលយោបល់និងវិភាគទាន

ពីសាកលវិទ្យាល័យ អង្គការ និងបុគ្គល ដែលជាសមាជិក ។

ព្រឹត្តិប័ត្រលេខ ២ ដែលត្រូវផ្សាយចេញក្នុងរយៈពេល ៦ ខែទៀត នឹងយកចិត្តទុកដាក់ទៅលើសកម្មភាពផ្សេង ៗ ដែលមាននៅក្រៅប្រទេសកម្ពុជា ជាពិសេសអំពីសមាជិកនៃសហាគម (ក្រុមស្ថាប័ន) និងបុគ្គលនិងក្រុមទាំងឡាយ ដែលជាអាយុជីវិតក្នុងការជួយបង្កើតមជ្ឈមណ្ឌល ។

ឧបសគ្គក្នុងការចូលអ៊ិនថឺរណិតពីស្រុកសៀមរាប រារាំងយើងខ្ញុំឲ្យរៀបចំគម្រោងការបង្កើតវ៉ិបសាយថ៍សម្រាប់មជ្ឈមណ្ឌល ។ ក៏ប៉ុន្តែ យើងខ្ញុំសង្ឃឹមថា អាចបង្កើតវាបានក្នុងពេលឆាប់ ៗ ដោយសារមានការឧបត្ថម្ភខាងការដឹកនាំពីសមាជិករបស់សហាគមខ្លះ ។

## _ ការរៀបចំបញ្ជីមូលដ្ឋានទិន្នន័យ ដែលរាយឈ្មោះមនុស្ស និងស្ថាប័នទាំងឡាយ ដែលមានចំណាប់អារម្មណ៍ទៅលើសិក្សាខ្មែរនៅប្រទេសកម្ពុជា និង នៅទូទាំងពិភពលោក

កញ្ញាសុវណ្ណាកំពុងធ្វើបញ្ជីមូលដ្ឋានទិន្នន័យ ដែលរាយឈ្មោះមនុស្ស និងស្ថាប័នដែលធ្វើការក្នុងវិស័យសិក្សាអំពីខ្មែរ ។ យើងខ្ញុំនឹងទទួលយោបល់ពីប្រិយមិត្តអ្នកអាន ដោយចិត្តត្រេកអរ ។

ក្នុងពេលឆាប់ ៗ នេះ ត្រូវជ្រើសរើសអ្នកស្រាវជ្រាវ ១ រូប នៅសហរដ្ឋ ដើម្បីអភិវឌ្ឍមូលដ្ឋានទិន្នន័យពត៌មាន ។ ការងារនេះសម្រាប់រកឲ្យឃើញនូវស្ថាប័នទូទាំងពិភពលោក ដែលបង្រៀន ឬ ធ្វើការស្រាវជ្រាវដែលទាក់ទងទៅនឹងវប្បធម៌ខ្មែរ ហើយការងារនេះ សម្រាប់ប្រមូលផ្តុំពត៌មានមកពីស្ថាប័នទាំងអស់នេះ ដែលនៅក្នុងនេះមាន ការបង្រៀនមុខវិជ្ជាទូទៅ គម្រោងមុខវិជ្ជាយថាប្រភេទ ហើយនិងសម្ភារៈយោងដែលនិស្សិតត្រូវការពិគ្រោះ ដើម្បីប្រមូលផ្តុំជាធនធានសម្រាប់មជ្ឈមណ្ឌល ។

នៅទីបញ្ចប់ ខ្ញុំបាទសូមគូសបញ្ជាក់ថា មជ្ឈមណ្ឌលខេមរសិក្សាជាស្ថាប័នដែលមានសភាពចំហនិងរាប់បញ្ចូល ។ លក្ខណៈ ១ របស់ ម.ខ.ស. គឺវាជាអង្គការអន្តរជាតិ ហើយដែលមានបំណងធ្វើសហប្រតិបត្តិការយ៉ាងសកម្ម ជាមួយសាកលវិទ្យាល័យកម្ពុជាទាំង ២ និងស្ថាប័ននានាក្នុងប្រទេស តែមជ្ឈមណ្ឌលក៏នៅតែរក្សាទុកបូរណភាពផ្នែកស្ថាប័ននិងផ្នែកបញ្ញវន្ត ។ នេះជាការចាំបាច់ ពុំអាចចៀសវាងបានទេ ដើម្បីទាញរកកម្មវិធីជារយៈពេលយូរយារ ពីស្ថាប័នបរទេសផ្សេង ៗ ដែលមានចំណាប់អារម្មណ៍ក្នុងវិស័យសិក្សាខ្មែរនិងអាស៊ីអាគ្នេយ៍ ។

តាមខ្ញុំបាទដឹង គម្រោងការនេះជាគំរូយ៉ាង ១ ដែលកម្រឃើញស្ដីពីសហប្រតិបត្តិការ ដែលមានគោលបំណងបង្រួបបង្រួមស្ថាប័នពីនានាប្រទេសនិងឯកទេសភាពផ្សេង ៗ ក្នុងគោលបំណងរួម ដែលជួយពង្រឹងស្ថានភាពសិក្សាកម្ពុជា នៅប្រទេសកម្ពុជាផង នៅប្រទេសជិតខាងដែលនៅអាស៊ីអាគ្នេយ៍ផង ។ ហើយនៅពេលដដែល មជ្ឈមណ្ឌលមាននាទីផ្សព្វផ្សាយចំណាប់អារម្មណ៍ទូទាំងពិភពលោក អំពីបេតិកភ័ណ្ឌវប្បធម៌ខ្មែរ ។

ក្នុងគំនិតបូរាណភាពនិងភាពទូលំទូលាយផ្នែកបញ្ញវន្ត ខ្ញុំបាទសូមអំពាវនាវដល់ប្រិយមិត្តអ្នកអានព្រឹត្តិប័ត្រសិក្សាចក្រ មេត្តាជួយគាំត្រយើងខ្ញុំដើម្បីឲ្យមជ្ឈមណ្ឌលខេមរសិក្សាប្រកបដោយជោគជ័យ ៕

# ក្រុម ម.ខ.ស. នៅដំណាក់កាលដំបូង

ការងារទាំងអស់នេះ គឺដើម្បីបង្កើតមជ្ឈមណ្ឌលឲ្យទៅជាស្ថាប័នដែលអាចឋិតថេរបាន និងដែលរស់រវើក បានធ្វើក្នុងកំឡុងពេលតែ ៥ ខែប៉ុណ្ណោះ ដោយសារតែការខិតខំរបស់មនុស្ស ១ ក្រុមតូច ដែលធ្វើការនៅសៀមរាប នៅដំណាក់កាលសំបូង ។ វត្តមានរបស់សមាជិក ដែលជាអ្នកស្រាវជ្រាវក្នុងវិស័យផ្សេង ៗ បានជួយឲ្យចាប់ផ្តើមកម្មវិធីផ្សេង ៗ ក្នុងពេលជាមួយគ្នា ។ អ្នកស្រាវជ្រាវបរទេសដែលជាសមាជិកនៅសៀមរាបឥឡូវនេះ ហើយដែលបានចូលរួមក្នុងការបង្កើតមជ្ឈមណ្ឌល គឺ លោក មីស្ហែល ឫទ្ធី អង់តែល្ម, បណ្ឌិត វិល្លៀម សោធវើរីធ និង លោក ហ្វ្រង់ស្វា តាំងទុយរីយ៉េ ។ ពួកគាត់ធ្វើការ ដោយមានការជួយពីកម្មសិក្សាការីខ្មែរ ២ នាក់ គឺ អ្នកស្រី ជាម ផល្លី និង កញ្ញា ណុព សុវណ្ណា ។

តាមលំដាប់អក្សរ ៖

**ជាម ផល្លី** ៖ អ្នកនាងផល្លី ជាស្ថាបត្យករដែលមានសញ្ញាប័ត្រពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅភ្នំពេញ ។ ទោះបីគាត់កំពុងធ្វើការពេញម៉ោង ក្នុងការងារជួសជុលស្តារប្រាសាទព្រះខ័ន របស់គម្រោងការមូលនិធិប្រាសាទបុរាណពិភពលោក ក៏ដោយ ក៏នាងបានឆ្លៀតយកពេលក្រោយម៉ោងធ្វើការ ដើម្បីធ្វើការជាមួយលោក ហ្វ្រង់ស្វា តាំងទុយរីយ៉េ ដើម្បីជួសជុលស្តារអគារសម្រាប់មជ្ឈមណ្ឌល នៅវត្តដំណាក់ ។

**ណុព សុវណ្ណា** ៖ នាងសុវណ្ណាបានមធ្យមសិក្សាប័ត្រពីវិទ្យាល័យខេត្តសៀមរាប ។ នាងជួយលោកមីស្ហែលនិងលោកវិល្លៀម ក្នុងការងាររបស់គាត់ ២ នាក់ ។ ជាមួយគ្នានេះ នាងក៏ទទួលបន្ទុកខាងផ្នែកគ្រប់គ្រង និង រៀបចំគណនេយ្យមជ្ឈមណ្ឌលឲ្យរៀបរយ ។

**មីស្ហែល ឫទ្ធី អង់តែល្ម** ៖ ជាជនជាតិបារាំងកាត់ខ្មែរ ហើយកំពុងធ្វើនិក្ខេបបទថ្នាក់បណ្ឌិត នៅសាលាសិក្សាបូព៌ាប្រទេសនិងអាហ្វ្រិក នៅទីក្រុងឡុងដ៍ ។ ប្រធានបទស្តីអំពីភាសាសាស្ត្រខ្មែរ ។ គាត់បានរៀបព្រឹត្តិប័ត្រលេខ ១ នេះ ចប់ដោយបរិបូណ៌ ។

**វិល្លៀម សោធវើរីធ** ៖ ជាបណ្ឌិតសញ្ជាតិប្រ៊ីតានិក (ជាជនជាតិអង់គ្លេស) ដែលបានធ្វើនិក្ខេបបទផ្នែកបុរាណវិទ្យានិងប្រវត្តិសាស្ត្របុរាណនៃអាស៊ីអាគ្នេយ៍ នៅសាលាសិក្សាបូព៌ាប្រទេសនិងអាហ្វ្រិក ។ លោកវិល្លៀមទទួលខុសត្រូវខាងផ្នែកប្រមូលគន្ថនិទ្ទេសអំពីបុរាណវិទ្យា និង ប្រវត្តិសាស្ត្រ ដែលទាក់ទងទៅនឹងប្រទេសកម្ពុជានិងអាស៊ីអាគ្នេយ៍ សម្រាប់អនាគតបណ្ណាល័យរបស់មជ្ឈមណ្ឌល ។

**ហ្វីលីព្ព ប៉ឺករ៉ាំ** ៖ ជាបណ្ឌិតបានធ្វើនិក្ខេបទថ្នាក់បណ្ឌិត ផ្នែកប្រវត្តិសាស្ត្រសម័យនៃអាស៊ីអាគ្នេយ៍ ពីសាលាសិក្សាបូព៌ាប្រទេសនិងអាហ្វ្រិកដែរ ។ ក្នុងឋានៈជានាយកស្តីទី លោកទទួលបន្ទុកនិងគ្រប់គ្រងការបង្កើតនិងអភិវឌ្ឍមជ្ឈមណ្ឌល ។

**ហ្វ្រង់ស្វា តាំងទុយរីយ៉េ** ៖ ជាជនជាតិបារាំង ហើយមានសញ្ញាប័ត្រខាងស្ថាបត្យកម្មនិងនគរោបនីយវិទ្យានៅប្រទេសបារាំង ហើយគាត់ក៏បានទទួលបរិញ្ញាទោផ្នែកវិទ្យាសាស្ត្រសង្គម ពីសាលា "បារត្លិត្ត" ដែលចូលក្នុងវិទ្យាស្ថានសាកលវិទ្យាល័យឡុងដ៍ ។ គាត់បានធ្វើឯកទេសកម្មខាងការជួសជុលស្តារបេតិកភ័ណ្ឌនៅអាស៊ីអាគ្នេយ៍ ។ គាត់ធ្វើការជាមួយអ្នកនាងផល្លី ក្នុងការជួសជុលស្តារអគារ ដែលសម្រាប់មជ្ឈមណ្ឌលនៅវត្តដំណាក់ ក្នុងក្រុងសៀមរាប ។

ក្នុងបញ្ជីនេះ គប្បីបន្ថែមឈ្មោះរបស់មនុស្សដែលបានចំណាយពេលវេលាយ៉ាងយូរ និងអត់ធ្មត់ ដូចជា អ្នកស្រី កីកូ មីអ៊ូរ៉ា ដែលកំពុងធ្វើនិក្ខេបបទថ្នាក់បណ្ឌិត, លោក ស៊ីន សុខន និង អ្នកស្រី ស៊ីន ហូ, កញ្ញា ជូលីយ៉ា បាយណ្ដិម៉ែន, កញ្ញា ណេរីដា អែឡុត្ត, កញ្ញា ស៊ីណ្ឌី កុល្វ៉ា, ហើយនិងលោក ឆាន ចំរើន ។ លោកចំរើនជាបុរាណវិទូធ្វើការក្នុងក្រុមមូលនិធិប្រាសាទបុរាណពិភពលោក ។ ឆ្លៀតឱកាសនេះដើម្បីសូមថ្លែងអំណរគុណចំពោះអស់លោក អ្នកស្រី និងនាងកញ្ញា ដែលបានចូលរួមនិងជួយជ្រោមជ្រែង ។